# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ ពិធីសម្ពោធជាផ្លូវការបង្គោលព្រំដែន នៅច្រកទ្វារអន្តរជាតិ បាវិត-ម៉ុកបាយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- យោងតាមសភាពការចាំបាច់ចំពោះមុខ។

## សម្រេច

**ប្រការ១.-** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីសម្ពោធផ្លូវការបង្គោលព្រំដែន នៅច្រកទ្វារអន្តរជាតិ បាវិត-ម៉ុកបាយ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ប្រាក់ សុខុន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម ជៀង អំ | អភិបាលខេត្តស្វាយរៀង | អនុប្រធាន |
| ៤- ឯកឧត្តម វ៉ា គីមហុង | ទីប្រឹក្សារាជរដ្ឋាភិបាល | សមាជិក |
| ៥- ឯកឧត្តម ប៊ុន សម | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម យូ ស៊ុនឡុង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |

៧- ឯកឧត្តម ជា សុខុម អគ្គលេខាធិការរងគណៈកម្មការបុណ្យជាតិ និងអន្តរជាតិ សមាជិក

៨-ឯកឧត្តម ពេជ្រ សូ ដេថ្លា អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៩-ឯកឧត្តម ឧត្តមសេនីយ៍ទោ ចាន់ អ៊ាន ប្រធាននាយកដ្ឋានកណ្តាលក្រសួងមហាផ្ទៃ សមាជិក

**ប្រការ២.-** គណៈកម្មការអន្តរក្រសួង មានភារៈកិច្ច :

- រៀបចំពិធីសម្ពោធបង្គោលព្រំដែន
- កំណត់ច្បាស់លាស់ទីតាំងសំរាប់នាយករដ្ឋមន្ត្រីទាំងពីរជួបបដិសណ្ឋារកិច្ច និងទីតាំងប្រារព្ធពិធីសម្ពោធ
- រៀបចំទីតាំងសំរាប់ប្រជាជន ចូលរួមពិធី
- ធានាបានសន្តិសុខ សុវត្ថិភាព នៃអង្គពិធីទាំងមូល
- ទំនាក់ទំនងជាមួយភាគីវៀតណាម អោយមានការឯកភាពគ្នា ក្នុងការរៀបចំពិធីនេះ អោយបានជោគជ័យ ។

**ប្រការ៣.-** គណៈកម្មការអន្តរក្រសួងនេះអាចបង្កើតអនុគណៈកម្មការមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**ប្រការ៤.-** គណៈកម្មការអន្តរក្រសួងនេះ ត្រូវរំសាយជាស្វ័យប្រវត្តិ ក្រោយពិធីសម្ពោធបង្គោល តាមច្រកព្រំដែនបាវិត-ម៉ុកបាយ បានបញ្ចប់ជាស្ថាពរ ។

**ប្រការ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ បណ្តាក្រសួងពាក់ព័ន្ធ និងឯកឧត្តម ដែលមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ស ខេង**

កន្លែងទទួល :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៤

-ឯកសារ-កាលប្បវត្តិ